# ភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព

## ឯកសារអាន

## សម្រាប់ការប្រជុំធ្វើផែនការរបស់ *DRC* នៅ *IDS*

## (ថ្ងៃទី២២-២៤ ខែវិច្ឆិកា ឆ្នាំ២០០០)


*សមាគមសម្រាប់ការស្រាវជ្រាវរួមនៅក្នុងទ្វីបអាស៊ី(PRlA)*

*42, Tughlakabad Institutional Area*

*New Delhi - 110062 ទូរស័ព្ទ: (91-11) 608 1908, 6089559*

*ទូរសារ: (91-11) 6080183 អ៊ីម៉ែល : infagpria.org*

*គេហទំព័រ: www.pria.org*

# ភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព ទស្សនៈវិស័យ


## សេចក្ដីសង្ខេប

*ដោយមិនរាប់បញ្ចូលនូវភាពក្រីក្រយ៉ាងខ្លាំង និងការខ្វះខាតក្នុងដំណើរការអភិវឌ្ឍបានធ្វើឱ្យមានការកើនឡើងនូវកង្វល់នានាចំពោះភាពជាប្រជាពលរដ្ឋដ៏សកម្ម ការចូលរួមរបស់ប្រជាជនប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាពនៅក្នុងដំណើរការធ្វើការអភិវឌ្ឍ។ តបនឹងកង្វល់ទាំងនេះ គឺតម្រូវឱ្យមានការរិះរកទម្រង់ផ្សេងៗគ្នានៃការអភិវឌ្ឍដែលជម្រុញឱ្យមានការរួបរួមគ្នាកាន់តែខ្លាំងក្លា និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ពីប្រជាពលរដ្ឋ។ មជ្ឈមណ្ឌលស្រាវជ្រាវការអភិវឌ្ឍ (DRC) ស្ដីពីភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព មានបំណងផ្ដោតកង្វល់បែបនេះទៅលើការរួបរួមគ្នា ការចូលរួម និងគណនេយ្យភាពនៅក្នុង បរិបទមួយផ្អែកលើសិទ្ធិ និងយកប្រជាពលរដ្ឋជាធំ ទាំងក្នុងទ្រឹស្ដី និងការអនុវត្តជាក់ស្ដែង។ នៅក្នុងប្រការនេះ ការលើកឡើងជា សង្ខេបនូវសាវតាររបស់ DRC ស្ដីពីភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព គឺបង្ហាញពីទស្សនៈវិស័យរបស់PRIA ស្ដីពី ទិដ្ឋភាពទាំងនេះ។*


## សាវតារ

ការព្រួយបារម្ភឈានទៅសម្រេចបាននូវការអភិវឌ្ឍ ដោយមិនលះបង់ចោលនូវគោលបំណងនៃការកាត់បន្ថយភាពក្រីក្រ គឺតម្រូវឱ្យ មានការគិតគូឡើងវិញស្ដីពីភាពជាប្រជាពលរដ្ឋរវាងប្រជាជនក្រីក្រ និងស្ថាប័ននានា ដែលមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគាត់។ ហើយវាក៏ជាការសំខាន់ផងដែរ ដែលត្រូវធ្វើការរិះរកនូវវិធីសាស្ត្រផ្សេងៗ ដែលអាចជួយជម្រុញឱ្យមានការរួបរួមគ្នាកាន់តែខ្លាំងក្លា និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់រវាងប្រជាពលរដ្ឋ និងរដ្ឋ។ បច្ចុប្បន្ននេះ ភាពជាប្រជាពលរដ្ឋដ៏សកម្ម ការចូលរួម របស់ប្រជាជនប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាពនៅក្នុងដំណើរការអភិវឌ្ឍ គឺជាកត្តាដ៏សំខាន់។ ការជួបពិភាក្សាទល់មុខគ្នា និងការពិភាក្សាផ្សេងៗជុំវិញដំណើការ មាតិការចនាសម្ព័ន្ធរៀបចំ យុទ្ធសាស្ត្រក្នុងការអនុវត្តប្រកបដោយភាពសកម្មការខិតខំប្រឹងប្រែងធ្វើការអភិវឌ្ឍ ដោយមានការចូលរួម និងប្រកបដោយការទទួលខុសត្រូវកំពុងត្រូវបានបង្កើតឡើង។ ជាលទ្ធផល ទស្សនាទាន ទ្រឹស្ដី វិធាន និងយុទ្ធសាស្ត្រមួយចំនួនត្រូវបានបង្កើតឡើង។ ការបង្កើត ***មជ្ឈមណ្ឌលស្រាវជ្រាវការអភិវឌ្ឍ (DRC) ស្ដីពីភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព*** គឺជាជំហានមួយក្នុងចំណោមនេះ។

*DRC* គឺជាសមាគមរបស់ដៃគូស្ថាប័នសហប្រតិបត្តិការមកពីប្រទេសចំនួន ៧ផ្សេងៗគ្នា រួមមាន ប្រទេសបង់ក្លាដេស ប្រេស៊ីល ឥណ្ឌា ម៉ិចស៊ិក នីហ្សេរីយ៉ា អាហ្វ្រិកខាងត្បូង និងចក្រភពអង់គ្លេស។ មជ្ឈមណ្ឌលនេះធ្វើការងារពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ ហើយមានគោលដៅរបស់ខ្លួនដូចខាងក្រោម :

- បង្កើតទម្រង់ថ្មីនៃភាពជាប្រជាពលរដ្ឋ ដែលនឹងជួយធ្វើឱ្យមានសិទ្ធិពិតប្រាកដ និងមានការចូលរួមដើម្បីប្រជាជនក្រីក្រ
- បង្កើតការពិភាក្សាស្តីពីការសន្និដ្ឋាន ការចូលរួម និងគណនេយ្យភាពនៅក្នុងបរិបទមួយផ្អែកលើសិទ្ធិ និងយកប្រជាពលរដ្ឋ ជាធំ ទាំងក្នុងទ្រឹស្តី និងការអនុវត្តជាក់ស្តែង។

ការទាមទារឱ្យមានការរួបរួមគ្នា គឺតម្រូវឱ្យមានសម្លេងពីប្រជាពលរដ្ឋ។ បញ្ហានេះតម្រូវឱ្យធ្វើការអភិវឌ្ឍនូវការយល់ដឹងកម្រិតខ្ពស់មួយពីថាតើប្រជាពលរដ្ឋមានការយល់ដឹងពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគាត់បានដល់កម្រិតណាពីមធ្យោបាយដែលត្រូវប្រើ ដើម្បីបង្កើនចំណេះដឹងរបស់ពួកគាត់ ជាលក្ខណៈបុគ្គល និងជារួម និងវិធីសាស្ត្រនានាដែលពួកគាត់អាចប្រមូលគ្នាដើម្បីធ្វើការទាមទារ អ្វីៗដែលពួកគាត់ចង់បាន។ យន្តការថ្មីដើម្បីឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋដោយផ្ទាល់ គឺនិយាយពាក់ព័ន្ធទៅនឹងដំណើរការ ទំនៀមទំលាប់ប្រពៃណី និងដំណើរការដែលបានបង្កើតឡើង ស្តីពីសិទ្ធិស្មើគ្នានៃអ្នកតំណាង និងផ្លាស់ប្តូរការពិភាក្សាស្តីពីការចូលរួមពី សំណាក់អ្នកទទួលផលនៅក្នុងគម្រោងអភិវឌ្ឍពាក់ព័ន្ធនឹងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងកិច្ចការផ្ទាល់របស់ពួកគាត់។ មានសំនួរដ៏សំខាន់មួយចំនួនដូចជា : តើសម្លេងរបស់នរណាខ្លះដែលគួរយកមកធ្វើការពិចារណា? តើមានអ្វីរារាំងទម្រង់នៃអំណាចដែល បានបង្កើតយូរណាស់មកហើយនោះមិនឱ្យធ្វើការង្កើតឡើងវិញបាន? តើទស្សនៈវិស័យណាមួយដែលប្រសើរជាង ហើយទស្សនៈ វិស័យណាមួយត្រូវបានបិទបាំង? ការកែប្រែនៃការយល់ដឹងពីសិទ្ធិ និងបរិបទថ្មីនៃការចូលរួមនាំឱ្យមានការពិចារណាឡើងវិញពីទំនាក់ទំនងនៃគណនេយ្យភាពតាមបែបប្រពៃណីក្នុងចំណោមវិស័យនានា ក្នុងបរិយាកាស និងកម្រិតផ្សេងៗគ្នា។ ជាមួយការចូលរួមពីប្រជាជនកាន់តែខ្លាំងឡើង តើទម្រង់នៃគណនេយ្យភាពអ្វីខ្លះដែលនឹងជួយធានាថា សម្លេងដែលកាន់តែកើនឡើងនេះពិតជាចូលរួមចំណែកដល់ការឆ្លើយតបជារួម និងស្របតាមគោលនយោបាយ? ស្របគ្នានេះដែរ *DRC* បានដៅនូវទិដ្ឋភាពស្រាវជ្រាវចំនួន ៣ គឺ ***(១) រូបភាព និងខ្លឹមសារ (I) សិទ្ធិ និងភាពជាប្រជាជន (II) ទំហំ កន្លែង និងឌីណាមិចនៃភាពជាប្រជាជន និង (III) គណនេយ្យភាព និងការទទួលខុសត្រូវ។*** តាមរយៈការអនុវត្តនូវវិធាននៃការវាស់វែងចម្រុះ និងវិធានចម្រុះ គឺមានគោលដៅស្វែងរកទិដ្ឋភាពទាំងនេះនៅក្នុង បរិបទផ្សេងៗគ្នា ប្រភេទនៃសិទ្ធិ កម្រិត និងការចូលរួមពាក់ព័ន្ធរបស់ប្រជាពលរដ្ឋតាមរយៈការសិក្សា និងការស្រាវជ្រាវដោយការ ធ្វើពិសោធន៍។ ក្នុងន័យនេះ មជ្ឈមណ្ឌលមានគម្រោងចូលរួមចំណែកធ្វើឱ្យមានការយល់ដឹងពីសក្តានុពលនៃទំហំថ្មីសម្រាប់សម្លេងរបស់ ប្រជាពលរដ្ឋ និងមានឥទ្ធិពលទៅលើគោល

នយោបាយអភិវឌ្ឍដែលកើតចេញពីទស្សនៈវិស័យចំពោះសិទ្ធិ និងភាពជាប្រជាពលរដ្ឋ។

តាមរយៈបរិបទចម្រុះនេះ ទាំងនៅតាមប្រទេស និងក្នុងចំណោមពួកគេផ្ទាល់ មជ្ឈមណ្ឌលនេះមិនមានទម្រង់ និងវិធីសាស្ត្រនៃការ ស្រាវជ្រាវជារួមទេ។ ដៃគូស្រាវជ្រាវម្នាក់ៗកំណត់នូវច្រកចូលយ៉ាងសំខាន់ឆ្ពោះទៅរកទស្សនាទានស្នូលពីបរិបទរបស់ពួកគេដែលមជ្ឈមណ្ឌលទាំងមូលចង់ចាប់យក។ ឧទាហរណ៍ ***PRIA-DRC*** (ឥណ្ឌា) មានគម្រោងពាក់ព័ន្ធផ្សេងៗគ្នាចំនួន ៣ : ***ខ្លឹមសារ និងអត្តសញ្ញាណនៃភាពជាប្រជាពលរដ្ឋនៅក្នុងរដ្ឋថ្មីមួយ (រូបភាព ខ្លឹមសារស្តីពីសិទ្ធិ និងភាពជាប្រជាពលរដ្ឋ) ការជាប់ទាក់ទងគ្នា ជម្រោះ និង ឌីណាមិចរវាងប្រពៃណី ការអភិវឌ្ឍ និងស្ថាប័នវិមជ្ឈការក្នុងស្រុក*** (ទំហំ ទីកន្លែង និងឌីណាមិចនៃការចូលរួមក្នុងភាពជាប្រពលរដ្ឋ) និង***គណនេយ្យភាពពហុភាគី*** (គណនេយ្យភាព និងការទទួលខុសត្រូវ)។ មជ្ឈមណ្ឌលនេះមានគោលបំណងធ្វើការជាមួយស្ថាប័ន ស្រាវជ្រាវក្នុងស្រុក និងក្រុមសង្គមស៊ីវិលនៅក្នុងរដ្ឋចំនួន ៣ផ្សេងៗ គឺ រដ្ឋ Jharkhand, Uttaranchal និងរដ្ឋ Maharashtra។

ទស្សនៈវិស័យរបស់ PRIA ស្តីពីភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព

សិក្ខាសាលាលើកដំបូងរបស់ *DRC ស្តីពីភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព* ត្រូវបានធ្វើឡើងនៅថ្ងៃទី ២២-២៤ ខែវិច្ឆកា ឆ្នាំ២000 នៅឯវិទ្យាស្ថានសិក្សាការអភិវឌ្ឍ ក្រុង Sussex ចក្រភពអង់គ្លេស។ គោលបំណងនោះគឺដើម្បីអភិវឌ្ឍការយល់ ដឹងផ្នែកគោលគំនិត និងបង្កើតរបៀបវារៈស្រាវជ្រាវរួមមួយ។ ឯកសារនិយាយពីជីវប្រវត្តិមួយចំនួនធំត្រូវបានគេបង្ហាញពាក់ព័ន្ធនឹងទិដ្ឋភាពនៃភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាពដែលបានបង្កើតជាមូលដ្ឋានសម្រាប់ធ្វើការអភិវឌ្ឍវិធានគោលគំនិតរួមមួយសម្រាប់ទិដ្ឋភាពសំខាន់នីមួយៗ និងបានផ្តល់នូវចំណុចចាប់ផ្តើមមួយសម្រាប់ការស្រាវជ្រាវនៅក្នុងពេលអនាគត។ លោកបណ្ឌិត Rajesh Tandon បានបង្ហាញនូវឯកសារពិនិត្យឡើងវិញនូវសាវតារស្តីពីទិដ្ឋភាពនៃ "ការចូលរួម"។ គាត់បានលើកឡើងនូវទស្សនៈ វិស័យរបស់ PRIA ដោយមានការផ្តោតជាបឋមលើបញ្ហាគន្លឹះមួយចំនួន ពាក់ព័ន្ធនឹង ***វិធានចំពោះការចូលរួម និងក្របខ័ណ្ឌគោល គំនិត ស្តីពីទិដ្ឋភាពនៃភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព។*** កំណុចគន្លឹះនៃបទបង្ហាញរបស់គាត់ត្រូវបានបង្ហាញឱ្យ ឃើញដូចខាងក្រោមនេះ។

**ក. វិធានចំពោះការចូលរួម : បញ្ហាគន្លឹះមួយចំនួន**

**វិធានជាប្រវត្តិសាស្ត្រចំពោះការចូលរួម**

វិធានជាប្រវត្តិសាស្ត្រចំពោះការចូលរួម គឺតម្រូវឱ្យសម្លឹងមើលទម្រង់ផ្សេងៗនៃការចូលរួម ទាំងក្នុងបរិបទប្រពៃណី និងសម័យទំនើប។ នៅក្នុងប្រទេសឥណ្ឌា ទម្រង់នៃការចូលរួមទាំងពីរនេះមានដំណើរស្របគ្នា។ មានទម្រង់នៃយន្តការចូលរួមតាមបែបប្រពៃណីតាមវណ្ណៈ ភូមិ ឬ សហគមន៍កុលសម្ព័ន្ធដើម។ ការចូលរួមទាំងនេះ គឺធ្វើឡើងដោយស្ម័គ្រចិត្ត ការផ្តួចផ្តើមរបស់ប្រជាជនដើម្បីជួយខ្លួនឯង ដែលកើតចេញពីសេចក្តីត្រូវការរបស់ពួកគេ តាមរយៈការកត់សម្គាល់មួយនូវការពឹងផ្អែករបស់ពួកគេទៅលើគ្នាទៅវិញទៅមក។ ក្រុមប្រជាជនកាន់ប្រពៃណីមានភាពឯករាជ្យ មួយផ្អែកដោយមានការដឹកនាំពីខាងក្រៅ។ វាបានផ្តល់នូវកន្លែងសម្រាប់ប្រជាពលរដ្ឋបង្ហាញពីតម្រូវការរបស់ពួកគេ ធ្វើការចរចារ និងមានឥទ្ធិពលលើការសម្រេចចិត្ត ដែលវាបានប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។ វាបានដើរតួយ៉ាងសំខាន់ក្នុងការតស៊ូរបស់ពួកគេដើម្បីយុត្តិធម៌ និងជីវិតល្អប្រសើរ និងបានជួយសម្រួលដល់ការរៀបចំសហគមន៍ និងសកម្មភាពសមូហភាព។

ការចូលរួមនៅក្នុងគម្រោងអភិវឌ្ឍទ្រង់ទ្រាយធំដោយមានការគាំទ្រពីរដ្ឋាភិបាល និងកម្មវិធីភ្នាក់ងារទ្វេរភាគី និងពហុភាគីបានដឹកនាំឆ្ពោះទៅរកការបង្កើតគណៈកម្មការអភិវឌ្ឍថ្នាក់ភូមិមួយចំនួនធំដែលជាវិស័យបឋម និងបានរៀបចំជាគម្រោង។ ច្បាប់វិសោធនកម្ម រដ្ឋធម្មនុញ្ញលើកទី ៧៣ នៅក្នុងឆ្នាំ១៩៩៣ តាមរយៈការធ្វើធម្មនុញ្ញកម្មស្ថាប័ន Panchayati Raj (PRIs) ដែលជាកង់ទី ៣នៃអភិបាលកិច្ច និង Panchayats ដែលជាស្ថាប័នគ្រប់គ្រងថ្នាក់មូលដ្ឋានដោយមានការបោះឆ្នោតនៅក្នុងមូលដ្ឋាន បានពង្រឹងការចូលរួម របស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍ។ ទម្រង់សម័យទំនើបនៃការរៀបចំ ដូចជាគណៈកម្មាធិការអប់រំភូមិ ឬ គណៈកម្មាធិការកែប្រែ និង ទម្រង់សម័យទំនើបនៃស្ថានប័នជាប់ឆ្នោតនៅក្នុងស្រុកត្រូវបានគេរៀបចំឡើងតាមរយៈការទំនាក់ទំនងលក្ខណៈផ្លូវការ។ ការរៀបចំទាំងនេះត្រូវបានណែនាំ និងដឹកនាំពីខាងក្រៅដើម្បីឆ្លើយតបទៅនឹងគោលបំណងនានាដែលបានកំណត់ទុកជាមុន។ នៅក្នុងប្រទេស ឥណ្ឌា ទម្រង់នៃការចូលរួមទាំងពីរបានកើតឡើងជាបន្តបន្ទាប់។ ភូមិប្រពៃណីបានបង្កើតការងារតាមរយៈស្ថាប័នក្នុងមូលដ្ឋានដែលជាប់ឆ្នោត។ ជាមួយនឹងវិធានជាប្រវត្តិសាស្ត្រនេះ យើងប្រឈមនឹងការមើលឃើញទម្រង់ទាំងពីរនេះមានជម្រោះនឹងគ្នា។

វិធានជាប្រវត្តិសាស្ត្រចំពោះការចូលរួម គឺត្រូវសម្លឹងមើលទម្រង់បែបប្រពៃណី និងវិធាននានាចំពោះការចូលរួម និងនៅពេលទន្ទឹមគ្នា នោះត្រូវសម្លឹងមើលវិធីដែលទម្រង់ទាំងនេះរៀបចំខ្លួនទៅជាទម្រង់សម័យទំនើប។ មានសេចក្តីត្រូវការមួយសម្រាប់ការពារទំនាក់ ទំនងកាន់តែធំនៅក្នុងស្ថាប័ន និងការសហការគ្នារវាងគណៈកម្មាធិការអភិវឌ្ឍនានា អង្គភាពវិមជ្ឈការមូលដ្ឋាន និងក្រុមប្រពៃណី។ ទំនាក់ទំនងនេះត្រូវការឱ្យមានការសិក្សាកាន់តែលម្អិតដើម្បីរកឱ្យឃើញនូវវិធានផ្សេងៗឆ្ពោះទៅធ្វើការសហការកាន់តែល្អប្រសើរក្នុង ចំណោមស្ថាប័នផ្សេងៗ។

## ថ្នាក់ក្រោម- វិធានរៀបចំពីថ្នាក់ក្រោមឡើងលើ

វាគឺជាជំនឿខុសដែលគិតថា ថ្នាក់ក្រោម គឺជាក្រុមដ៏សាមញ្ញ និងមានភាពក្រីក្រដូចគ្នា ហើយមិនមានអ្វីសោះនោះ។ ផ្ទុយទៅវិញពួកគេ ជាក្រុមដែលមានចំណាត់ថ្នាក់ខ្ពស់។ ការទទួលយកបញ្ហាត្រួតពិនិត្យ និងភាពជាម្ចាស់កម្មសិទ្ធិនេះជាចំណុចបែកបាក់ យើងបានរកឃើញ ថាភាពខុសគ្នាកើតមាននៅក្នុងថ្នាក់ក្រោមនីមួយៗ។ ភាពខុសគ្នានេះមានភាពជ្រាលជ្រៅ និងមានភាពស្មុគស្មាញយ៉ាងខ្លាំងបំផុតនៅ ក្នុងប្រភេទនៃវណ្ណៈ ថ្នាក់ យែនឌ័រ និងអំបូរជាតិសាសន៍។ តាមរយៈការមើលទំនាក់ទំនងនៃអំណាចខាងក្នុងយ៉ាងខ្លាំងក្លា និងផលិតកម្ម នៅក្នុងប្រព័ន្ធសង្គម យើងអាចវាយតម្លៃពីសកម្មភាពអន់ថយនៃគម្លាតដែលរួញខ្លី និងជជ្រើសនៃផ្នែកផ្សេងៗគ្នានៃថ្នាក់ក្រោម។ ទស្សនៈស្រដៀងគ្នាយ៉ាងខ្លាំងនៅថ្នាក់ក្រោមនឹងត្រូវយកមកធ្វើការពិចារណាពីកាឡោន និងជួរនៃការចូលរួមរវាងព័ត៌មាន និងទំនាក់ ទំនងខ្សែបញ្ឈរ និងខ្សែផ្ដេក។

## អត្ថន័យតាមវប្បធម៌ និងនយោបាយនៃការចូលរួម

ជាទូទៅការពិភាក្សា គឺផ្ដោតទៅលើអត្ថន័យនៃការចូលរួមតាមបែបនយោបាយ។ អត្ថន័យនយោបាយ គឺត្រូវបានផ្សារភ្ជាប់ដោយខ្វះមិនបានជាមួយនឹងទំនាក់ទំនងរបស់ប្រជាជានជាមួយនឹងរដ្ឋ។ ប្រជាជនត្រូវបានគេកំណត់ថា ជាអ្នកទទួលផល ឬជាអ្នកបោះឆ្នោត។ ប្រជាជនអាចជាអ្នកទទួលអំណោយពីរដ្ឋាភិបាល ឬ ការជួយឧបត្ថម្ភ ឬ កម្មវិធីអភិវឌ្ឍ ដែលមានន័យថា អ្នកដេក ហើយរដ្ឋចែកចាយ ឬ ជាអ្នកបោះឆ្នោត ដែលមានន័យទៅតាមពេលវេលាថា អ្នកប្រើសន្លឹកឆ្នោតរបស់អ្នក ហើយបំភ្លេចវាចោល។

ប្រជាពលរដ្ឋនៅក្នុងប្រទេសឥណ្ឌាក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរកំពុងតែចាប់ផ្ដើមមិនជឿជាក់ទៅលើស្ថាប័នរដ្ឋ និងភ្នាក់ងាររាជរដ្ឋាភិបាល។ ពួកគេចាប់ផ្ដើមមិនយកចិត្តទុកដាក់ចំពោះការអភិបាល និងការពឹងផ្អែកទៅលើរដ្ឋសម្រាប់សុខមាលភាពរបស់ពួកគេ។ នេះគឺជាបញ្ហាមួយដែលយើងបានរកឃើញក្នុងការសិក្សាមួយដែលយើងឱ្យឈ្មោះថា "ប្រជាពលរដ្ឋ និងអភិបាលកិច្ច"។ ការសិក្សានេះគ្របដណ្ដប់ទៅលើប្រទេស Commonwealth។ នៅក្នុងអំឡុងពេលសិក្សាយើងបានពិនិត្យទៅលើសំណួរដែលថា តើប្រជាពលរដ្ឋរំពឹងចង់បានអ្វីពីខ្លួនគេផ្ទាល់? នៅក្នុងសំលេងប្រជាជនមានការទាមទារដ៏សមរម្យមួយគឺមិនត្រូវប្រព្រឹត្តមកលើពួកគេដើម្បីទាញយកផលប្រយោជន៍ផ្នែកកម្មវិធី ឬ ផែនការណ៏នយោ បាយឡើយ ហើយក៏មិនត្រូវចាត់ទុកពួកគេជាអ្នកបោះឆ្នោតដែលបោះឆ្នោតជ្រើសតំណាងរបស់ខ្លួនម្ដងម្កាលដែរ គឺត្រូវចាត់ទុកពួកគេជាប្រជាពលរដ្ឋ។

ការសិក្សាបន្ថែមរបស់ពួកយើងបានបង្ហាញថា ប្រជាជនបានគិតថាខ្លួនគេផ្ទាល់ជាប្រជាពលរដ្ឋក្នុងន័យនយោបាយ-ទំនាក់

ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋឡើយ។ ការកើនឡើងនៃការបែកខ្ញែកពីរដ្ឋ ធ្វើឱ្យមានការកើនឡើងនូវការដាច់ចេញពីគេនូវក្រុមមនុស្សមួយផ្នែក ធំដែលបដិសេធមិនព្រមទទួលយកស្ថាប័នរដ្ឋ និងរចនាសម្ព័ន្ធវប្បធម៌នៃសហគមន៍ និងលំនៅរបស់ខ្លួន។ ជាឧទាហរណ៍ក្រុមអន្តោប្រវេសន៍មួយក្រុមមកពី Kerala ដែលធ្វើដំណើរទៅកាន់ Gulf ដើម្បីស្វែងរកការងារធ្វើមានអារម្មណ៍ថាពួកគេហាក់ដូចជា មិនមែនជាជនជាតិឥណ្ឌានៅពេលដែលគេត្រឡប់មកប្រទេសឥណ្ឌាវិញ។ ស្ថានការចាស់ដែលជិតដាមនោះគឺសង្គ្រាមនៅឈូងសមុទ្រនៅឆ្នាំ ១៩៩១ នៅពេលរដ្ឋបានបោះបង់ចោលមនុស្សទាំងនេះ។ គេមិនត្រឹមតែមិនមែនជាជនជាតិគុយវ៉ែតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនមែនជាជនជាតិឥណ្ឌាទៀតផង។ ប៉ុន្តែពួកគេបែជាមើលឃើញខ្លួនគេថាជាប្រជាពលរដ្ឋក្នុងផ្នែកវប្បធម៌ទៅវិញ។ អត្ថន័យជាវប្បធម៌នៃភាពជាពលរដ្ឋគឺវាខុសគ្នាពីន័យនយោបាយ។ ការបកស្រាយតាមបែបសីលធម៌នៃការចូលរួមត្រូវបានគេភ្ជាប់ ទៅនឹងអារម្មណ៍ថាជាកម្មសិទ្ធិ និង ការទទួលខុសត្រូវ។ អារម្មណ៍របស់មនុស្សនៃភាពជាកម្មសិទ្ធិ និងភាពទទួលខុសត្រូវ ត្រូវបាននាំយកមកកាន់តែច្រើនមក កាន់សហគមន៍ការរាប់រកគ្នាជាបងប្អូន និងក្រុមជាសាច់ញាតិរបស់ពួកគេ។

ការកើនឡើងនូវសំឡេងរបស់ប្រជាពលរដ្ឋគឺជាការប្រកួតប្រជែងដ៏ចំបងដែលយើងកំពុងជួបប្រទះសព្វថ្ងៃនេះ។ ដូច្នេះហើយទើបបញ្ហាសំខាន់ គឺការកែប្រែរចនាសម្ព័ន្ធប្រព័ន្ធ និងអង្គការ ដែលជួយការសិទ្ធិ និងសិរីភាពអ្នកក្រ និងជនដែលគេបោះបង់ចោល។ តម្រូវឱ្យមានការគិតឡើងវិញមួយទៅលើ "ការធ្វើនយោបាយនីយកម្មនៃការចូលរួមរបស់ប្រជាពលរដ្ឋ" គឺថាមិនត្រឹមតែក្នុងន័យនៃ ការបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែក្នុងន័យជាមូលដ្ឋាននៃភាពជាពលរដ្ឋសកម្ម។ ទស្សនៈនៃភាពជាប្រជាពលរដ្ឋដែលត្រូវបានគេផ្តល់ព័ត៌មានឱ្យដឹង ផ្តល់អំណាច និងសកម្មគឺមិនទាន់ត្រូវបានគេយល់ទាំងស្រុងនោះឡើយ ហើយត្រូវជជែកវែកញែកគ្នានៅក្នុងបរិបទរបស់យើង។

ការយល់ឃើញចំពោះភាពជាពលរដ្ឋសកម្មគឺផ្អែកទៅលើភាពផ្សេងគ្នានៃវប្បធម៌ និងអត្តសញ្ញាណច្រើន ព្រមទាំងលំដាប់នៃប្រព័ន្ធផ្សេងៗ នៃការរស់រានមានជីវិត និងការទ្រទ្រង់ផងដែរ។ ការចូលរួមលិទ្ធិប្រជាធិបតេយ្យដោយផ្ទាល់តម្រូវឱ្យមានការអត់ធ្មត់ចំពោះភាពផ្សេងគ្នានៃវប្បធម៌ច្រើន និងទស្សនៈវិស័យចំពោះសកម្មភាពរបស់ពលរដ្ឋ។

## សញ្ញាណផ្សេងគ្នា និង សញ្ញាណរួមនៃភាពជាប្រជាពលរដ្ឋ

ការយល់ឃើញទៅលើសញ្ញាណផ្សេងគ្នានៃភាពជាប្រជាពលរដ្ឋត្រូវបានគេភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ទៅនឹងការថ្លែងពីភាពដែលសមនឹងទទួលបាន ការផ្តល់សិទ្ធិ និងកិច្ចសន្យាស្របច្បាប់។ វាលើសលុបទៅលើងអត្តសញ្ញាណរួមនៃភាពជាសាច់ញាតិ វណ្ណៈ និងសហគមន៍ ដែលដូច្នេះហើយទើបវាបដិសេធទៅនឹងគោលការណ៍ដែលជាមូលដ្ឋានមួយចំនួនរបស់សហ

គមន៍ និងអត្តសញ្ញាណដែលសំអាងលើហេតុផល។ ភាពជាសាច់ញាតិ វណ្ណៈ សហគមន៍ កាតព្វកិច្ចសង្គម ទំនាក់ទំនងវប្បធម៌ និងបែបផែននៃសាសនានៃការចូលរួម គឺប្រមូលផ្តុំជាប្រពៃណីក្នុងលក្ខណៈជាធម្មជាតិ ដោយតម្រូវឱ្យមានការចូលរួមយ៉ាងសកម្ម និងភក្តីភាពមួយចំនួន។ នៅក្នុងសង្គមស៊ីវិល ជនជាតិដើមភាគតិចទាំងនេះ គេត្រូវការសេវាសាធារណៈសម្រាប់ការចែករំលែករបស់វាទៅកាន់ភាពរីកចំរើននៃផលល្អជារួម។ ក្របខ័ណ្ឌ ការងារនៃផលល្អជារួម ដូចដែលបានកំណត់ន័យដោយសហគមន៍ជនជាតិដើមភាគតិចនៅក្នុងបិរបទរួមក្នុងក្របខ័ណ្ឌការងារដ៏ធំមួយនៃភាពល្អជាទូទៅ គឺប្រឆាំងទៅនឹងសិទ្ធិបុគ្គល និងការបង្កើនឡើង។ ក្នុងបរិបទរបស់ពួកយើង យើងមិនមែនពិតជាដើរក្រោយសម័យដែលផ្អែកទៅលើការសន្និដ្ឋាននៃការលើកទឹកចិត្តបុគ្គលមួយឱ្យចាប់យកចំណាប់អារម្មណ៍របស់ខ្លួនឯងឡើយ។ តាមពិតយើងស្ថិតនៅទីតាំងណាមួយនៅចន្លោះរវាងរដ្ឋក្រោយប្រពៃណី និងមុនសម័យទំនើប។ ជាលទ្ធផល ភាពទាក់ទងគ្នារួមគឺមិនអាចចៀសវាងបានឡើយ។

ផ្អែកផ្សេងគ្នានៃការថ្លែងអំពីភាពជាប្រជាពលរដ្ឋផ្តល់នូវទំរង់ដែលមានការប៉ះទង្គិចគ្នានៃការធ្វើឱ្យត្រឹមត្រូវតាមច្បាប់។ ទន្ទឹមនឹងនេះ ការថ្លែងដែលផ្ទុយគ្នាទាំងនេះគឺមានទំនាក់ទំនងគ្នា ដែលក្រុមមនុស្សផ្សេងគ្នារួមសហការណ៍គ្នាតស៊ូដើម្បីការទទួលស្គាល់ និងធនធាន។ ជួនកាលមានភាពតឹងតែងទៅលើសិទ្ធិ និងកាតព្វកិច្ច ដោយសារតែភាពភ្ជាប់មកជាមួយនូវសញ្ញាណរៀងៗខ្លួននៃភាពជាពលរដ្ឋ ជាមួយនឹងការអះអាង និងកាតព្វកិច្ចទាំងនោះដែលម្នាក់រីករាយធ្វើជាសមាជិកនៃភាពជាបងប្អូន វណ្ណៈ សហគមន៍ វប្បធម៌សង្គម និងក្រុមសាសនា ដែលទំរង់នៃការចូលរួមប្រមូលផ្តុំគ្នាតាមលក្ខណៈធម្មជាតិ។ ផ្ទុយមកវិញ សិទ្ធិជារួមអាចធ្វើឱ្យមានភាពតានតឹងរវាងគ្នា និង គ្នា។ សមាជិកផ្សេងគ្នានៅក្នុងក្រុមដែលរស់នៅប្រកួតប្រជែងគ្នា ដើម្បីទទួលបាននូវធនធាន និងការទទួលស្គាល់។

ចាំបាច់ត្រូវមានការត្រួតពិនិត្យទៅលើទំនាក់ទំនងរវាងបុគ្គល និងសមូហភាព និងអត្ថន័យដែលវាមានសម្រាប់ទម្រង់ក្នុងការចូលរួម និងសិទ្ធិក្នុងការចូលរួម។ វានឹងជួយឱ្យកាន់តែប្រសើរឡើងដល់ ការគ្រប់គ្រង អន្តរាគមន៍ការអភិវឌ្ឍ សម្រួលដល់ការគ្រប់គ្រងល្អ និងពង្រឹងការចូលរួមរបស់ពលរដ្ឋទៅក្នុង "ការកំណត់អនាគតផ្ទាល់ខ្លួនរបស់ពួកគេតាមលក្ខណៈដែលបន្ត និងជួយគាំទ្រ"

## ខ. ក្របខ័ណ្ឌទស្សនៈ : ហេតុផលពីរដែលគ្របគណ្តប់លើអ្វីៗគ្រប់យ៉ាង

## អត្ថន័យនៃពាក្យសាធារណៈ

កាយល់ដឹងថ្មីៗបានចេញជាលទ្ធផលនូវនិយមន័យមួយ ដែលមានលក្ខណៈជាឯកជនជាមួយអ្វីដែលស្របគ្នានៅក្នុងគ្រួសារ និង សាធារណៈ ជាមួយអ្វីដែលផ្តល់កង្វល់ដល់រាជរដ្ឋាភិបាល។ ចាំបាច់ត្រូវធ្វើសារជាថ្មីនូវការយល់របស់យើងអំពីអ្វីទៅសាធារណៈ ហើយអ្វីទៅឯកជន។ វាសំខាន់ណាស់ដែលត្រូវទទួលស្គាល់នូវគំនិតឯកជនក្លាយជាមូលដ្ឋានចូលរួមក្នុងតំណែងសាធារណៈ ហើយសំណួរដែលមានលក្ខណៈជាឯកជនគឺជាបញ្ហាដែលពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌការងារដ៏ទូលំទូលាយនៃសហគមន៍។ ស្រដៀងគ្នានេះដែរ អ្វីដែលជាចំណាប់អារម្មណ៍សាធារណៈ អ្វីដែលកង្វល់របស់វេទិកាសាធារណៈមិនមែនជាកង្វល់របស់រដ្ឋ ឬ ភ្នាក់ងារនានារបស់វាឡើយ។

មានបញ្ហា ៣ចំពោះអត្ថន័យនៃពាក្យសាធារណៈ។ ទីមួយគឺ "សាធារណៈល្អ"។ នៅក្នុងបរិបទរបស់ពួកយើង យើងព្រួយបារម្ភណ៍បង្ហាញថាតើ public good ត្រូវបានបង្កើតឡើងតាមរបៀបណា ហើយវាត្រូវបានគេតវ៉ារបៀបណា និងរាល់មតិជំនាញទូទៅទាំងអស់ សូម្បីតែមិនទៅដល់មតិទូទៅជាអចិន្ត្រៃក៏ដោយ។ និយាយដោយត្រង់ នៅក្នុងសង្គម OUT មិនមានមតិទូទៅ 'public good' ឡើយឥឡូវនេះ។ មានការតវ៉ាគ្នាទៅលើគ្រប់ផ្នែកទាំងអស់ពីការអប់រំជាមូលដ្ឋានចំពោះសកលភាវូបនីយកម្ម។ ផ្នែកទាំងមូលត្រូវបានគេតវ៉ា។

បញ្ហាទីពីរគឺអំពី "ស្ថាប័នសាធារណៈ"។ យើងបង្កើនការជឿជាក់ថាស្ថាប័នសាធារណៈមិនមែនគ្រាន់តែមានន័យថា ជាស្ថាប័នរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ។ យើងជឿជាក់ថាវាបានដាក់បញ្ចូលនូវរាល់ស្ថាប័នទាំងអស់ដែលប្រតិបត្តិក្នុងសង្គមក្នុងលក្ខណៈជាសាធារណៈ។ ស្ថាប័នឯកជនដែលបង្កើនប្រើប្រាស់ធនធានសាធារណៈ អង្គការសង្គមស៊ីវិល និង NGOs គឺសុទ្ធតែជាស្ថាប័នសាធារណៈ ដោយសារ តែគេបានប្រតិបត្តិនៅក្នុងទីអសាធារណៈ ហើយដើរតួលើបញ្ហាសាធារណៈ។

នេះនាំទៅរកបញ្ហាទី៣ 'គណនេយ្យភាពសាធារណៈ '។ យើងមានចំណាប់អារម្មណ៍ជាពិសេសទៅលើអ្វីដែលយើងកំពុងចាប់ផ្តើមហៅថា គណនេយ្យភាពពហុភាគី។ យើងកំពុងចាប់ផ្តើមពិសោធន៍ជាមួយនឹងភាគីដែលមានទំនួលខុសត្រូវលើគ្នានៅពេលដែលបានប្រឈមមុខ នឹងសញ្ញាណផ្សេងៗគ្នាដែលមានទំនួលខុសត្រូវតាមវិធីតែមួយ។

## ដំណើរការអភិបាលកិច្ច

កម្រិតទី២ ទាក់ទងទៅនឹងទស្សនៈ៣ នៃភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព។ វាជាប្រធានបទមួយដែលត្រូវពិភាក្សា ជាលក្ខណៈ ផ្ទាល់ខ្លួន និងដោះស្រាយវា ដោយម្នាក់ឯង ប៉ុន្តែវាអាចមានតម្លៃ នៅពេលគិតអំពីថា តើវាត្រូវគ្នាដោយវិធីណានោះ។ ខ្ញុំមើលទៅពួកវា ចំនួន៣ ជាមួយគ្នានៅពេលដែល 'ដំណើរការអភិបាលកិច្ច'។ យើងត្រូវការ

មើលទៅរបៀបដែលការចូលរួមធានានូវគណនេយ្យភាព និងថាតើទស្សនៈសញ្ជាតិបង្កលទ្ធភាពដល់ការចូលរួមបែបណា ។

ការចូលរួមគឺនិយាយអំពីការចូលរួមរបស់អ្នកដែលមានចំណែក រដ្ឋ និងមិនមែនរដ្ឋ តាមរយៈដំណើរការនៃទំនាក់ទំនង និងការចរចា ដើម្បីមានឥទ្ធិពលលើការសម្រេចចិត្ត ដែលជះឥទ្ធិពលដល់ជីវិតរស់នៅរបស់ពួកគាត់ ។ ការចូលរួមនាំទៅរកការបង្កើត និងការធ្វើឱ្យ គណនេយ្យភាពមាននិរន្តភាព ។ តាមពិតទៅ គណនេយ្យភាព គឺជាមូលដ្ឋានតែមួយគត់ដែលប្រជាពលរដ្ឋអាចធ្វើទៅបាន ។ វានាំទៅរក ភាពបើកចំហ និងតម្លាភាពនៅក្នុងការធ្វើគោលនយោបាយ ។ គណនេយ្យភាពបង្កើតនូវតួនាទីចំពោះគ្នាក្នុងសង្គម ដែលធ្វើដោយភាព ស្មើគ្នា ការអត់ឱនរវាងក្រុម និងសញ្ជាតិរួមគ្នា។ ជាការទទួលមកវិញ ប្រជាពលរដ្ឋដែលមានទំនួលខុសត្រូវ និងមានភាពសកម្មនឹង ទទួលបានការចូលរួមដែលប្រកបដោយអត្ថន័យ ។

នៅមានទស្សនៈមួយទៅលើកម្លាំងរួមខាងក្នុង ក្នុងចំណោមប្រជាពលរដ្ឋ គណនេយ្យភាព និងការចូលរួម ។ សញ្ជាតិបានផ្តល់សិទ្ធិក្នុងការទទួលខុសត្រូវ និងគណនេយ្យភាពរបស់អ្នកដទៃ គឺជាដំណើរការនៅក្នុងការចូលរួម ។ ប្រជាពលរដ្ឋដែល




មានភាពសកម្មនឹងមានឱកាសស្វែងរកគណនេយ្យភាពកាន់តែទូលំទូលាយពី អ្នកផ្តល់សេវាកម្មតាមរយៈការសន្ទនា និងការប្រឹក្សាដែលបានកើនឡើង និងដោយការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្ត ការងារខាងក្រៅ និងទ្វេភាគី ។ ទស្សនៈនៃសញ្ជាតិស្ថិតនៅលើទស្សនៈនៃសិទ្ធិសង្គម ទំនួលខុសត្រូវសង្គម និងគណនេយ្យ ភាពសង្គម ។ ដូច្នេះហើយ គណនេយ្យភាព ដែលបានបង្កើតឡើងដោយប្រជាពលរដ្ឋដែលមានភាព សកម្មនឹងមានការចូល រួមជាសំខាន់ ។ ដូច្នេះ វាមិនមានបញ្ហាជាមួយនឹងគោលនយោបាយរបស់អ្នកផ្សេងទៀត និងការចូលរួមរបស់អ្នកផ្សេង ទៀតនោះទេ ។

តាមវិធីណាមួយក៏បាន ប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព នឹងបង្កើតមូលដ្ឋាននៃ 'ដំណើរការអភិបាលកិច្ច' នៅក្នុងលក្ខណៈដែលចូលរួមគ្នា ទាក់ទងគ្នា សហការជោគជ័យ និងមានឥទ្ធិពលលើគ្នានៅក្នុងទំនាក់ទំនងដែលប្រកបដោយថាមពល ។ ប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព គឺពិតជាសរសរទ្រូងនៃអភិបាលកិច្ចសំខាន់ មិនគ្រាន់តែនៅក្នុងស្ថាប័នអភិបាលកិច្ចទេ ប៉ុន្តែនៅក្នុងស្ថាប័នទាំងអស់ដែលកាន់កាប់កន្លែងសាធារណៈ ។

---

*ប្រការនេះគឺផ្អែកទៅលើបទបង្ហាញដែលធ្វើឡើងដោយបណ្ឌិត Rajesh Tandon នៅក្នុងសិក្ខាសាលាលើកដំបូងរបស់ "មជ្ឈមណ្ឌលស្រាវជ្រាវការអភិវឌ្ឍស្តីពីភាពជាប្រជាពលរដ្ឋ ការចូលរួម និងគណនេយ្យភាព" ថ្ងៃទី២២-២៤ ខែវិច្ឆិកា ឆ្នាំ២000 នៅឯ IDS ទីក្រុង Sussex ចក្រភពអង់គ្លេស ។*